ChTy

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: [illegible] ប្រក.កសក

# ប្រ កា ស

## ស្តីពី

## ការកែសម្រួលឈ្មោះប្រភេទសត្វព្រៃ ចំនួន ៥ ប្រភេទ និង ធ្វើចំណាត់ថ្នាក់សត្វព្រៃចំនួន ៦ ប្រភេទក្នុងឧបសម្ព័ន្ធ នៃប្រកាសលេខ ០២០ ប្រក.កសក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះនាយកដ្ឋានរុក្ខាប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.បុ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់រដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ០២០ ប្រក.កសក.បុ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្តីពីចំណាត់ថ្នាក់ និង បញ្ជីឈ្មោះប្រភេទសត្វ
- តាមសំណើរបស់ប្រធានរដ្ឋបាលព្រៃឈើ

## ស ម្រេ ច

**ប្រការ១.-** ត្រូវបានកែសម្រួលឈ្មោះប្រភេទសត្វព្រៃ ចំនួន ៥ ប្រភេទ និង ធ្វើចំណាត់ថ្នាក់សត្វព្រៃ ចំនួន ៦ ប្រភេទ ក្នុងឧបសម្ព័ន្ធ នៃ ប្រកាសលេខ ០២០ ប្រក.កសក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដូចខាងក្រោម :

## ១_ ការកែសម្រួលឈ្មោះប្រភេទសត្វព្រៃ :

### ក-ឈ្មោះបញ្ជីបច្ចុប្បន្ន

| ល.រ | ឈ្មោះខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអង់គ្លេស | សាយតេស |
|---|---|---|---|---|
| ក្រុមប្រភេទមានដោយកម្រ | | | | |
| ១៨ | ទោចថ្ពាល់លឿង | Hylobate gabriellae | Yellow-cheeked gibbon | I |
| ២៤ | រញ្ជឺផេះ | Nycticebus coucang | Slow loris | II |
| ២៦ | ស្វាក្រវ៉ាត់ ឬ ស្វាកន្ទុយស | Pygathrix nemaeus | Douc Langur | I |
| ក្រុមប្រភេទមានដោយបង្គួរ | | | | |
| ៤៥ | ស្វាគ្រោស | Macaca nemestrina | Pig-tailed Macaque | II |
| ៤៦ | ស្វាព្រាម | cristatus | Silvered Langur | II |

### ខ-ឈ្មោះកែសម្រួលថ្មី

| ល.រ | ឈ្មោះខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអង់គ្លេស | សាយតេស |
|---|---|---|---|---|
| ក្រុមប្រភេទមានដោយកម្រ | | | | |
| ១៨ | ទោចថ្ពាល់លឿង | Nomascus gabriellae | Yellow-cheeked crested gibbon | I |
| ២៤ | រញ្ជឺផេះ | Nycticebus bengalensis | Northern slow loris | I |
| ២៦ | ស្វាក្រវ៉ាត់ ឬ ស្វាកន្ទុយស | Pygathrix nigripes | Black-shanked douc langur | I |
| ក្រុមប្រភេទមានដោយបង្គួរ | | | | |
| ៤៥ | ស្វាគ្រោស | Macaca leonina | Northern pig-tailed macaque | II |
| ៤៦ | ស្វាព្រាម | Trachypithecus germaini | Silvered Langur | II |

## ២_ ការធ្វើចំណាត់ថ្នាក់សត្វព្រៃ :

| ល.រ | ឈ្មោះខ្មែរ | ឈ្មោះវិទ្យាសាស្ត្រ | ឈ្មោះអង់គ្លេស | សាយតេស |
|---|---|---|---|---|
| ក្រុមប្រភេទមានដោយកម្រ | | | | |
| ០១ | អណ្តើកគីកតាល់បន្លាមួយ | Manouria impressa | Impressed tortoise | II |
| ក្រុមប្រភេទមានដោយបង្គួរ | | | | |
| ០១ | ភេខ្លួនរលោង | Lutrogale perspicillata | Smooth otter | II |
| ០២ | ភេតូច | Aonyx cinerea | Oriental small-clawed otter | II |
| ០៣ | អណ្តើកព្រិច | Indotestudo elongata | Elongated tortoise | II |
| ០៤ | អណ្តើកបិទមុខស្នូកខ្មៅ | Cuora amboinensis | Asian box turtle | II |
| ០៥ | ឆ្មាបា | Cynocephalus variegatus | Sunda colugo | |

<u>ប្រការ២._</u> ក្រោយពីការកែសម្រួលឈ្មោះប្រភេទសត្វព្រៃ និង ការធ្វើចំណាត់ថ្នាក់សត្វព្រៃក្នុងឧបសម្ព័ន្ធ ខ្លឹមសារទាំងឡាយ នៃ ប្រកាសលេខ ០២០ ប្រក.កសក ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវបានរក្សាទុកដដែល ។

**ប្រការ៣.-** អគ្គនាយកនៃក្រសួង អគ្គាធិការ សមត្ថកិច្ចគ្រប់គ្រងសាយតេសកម្ពុជា នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ ប្រធានអង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទដែលពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០៧

រដ្ឋមន្ត្រី

ច័ន្ទ សារុន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្ដីការគណៈរដ្ឋមន្ត្រី

ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
ក្រសួងយុត្តិធម៌
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ក្រសួងបរិស្ថាន
គ្រប់សាលាខេត្ត-ក្រុង
ដូចប្រការ៣
ឯកសារ - កាលប្បវត្តិ